មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង
ជំងឺអេដស៍ សើស្បែក និង

## សិក្ខាសាលាថ្នាក់តំបន់ ស្តីពី «ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥»




មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គសិក្ខាសាលាថ្នាក់តំបន់ស្តីពី « **ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥** » ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៥ នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកែបដោយមានការគាំទ្រថវិកា និងបច្ចេកទេសដោយគម្រោង US-CDC Cambodia ។ គោលបំណង





នៃសិក្ខាសាលានេះគឺដើម្បីជាជាន្ធវលទ្ធផល និងសមមាត្រខ្ពស់នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ចុះឈ្មោះ ទទួលសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព ។ សិក្ខាសាលានេះក្រោមអធិបតី **លោកវេជ្ជ. ង៉ូវ ប៉ូក** អនុប្រធានមជ្ឈ-មណ្ឌលជាតិ

ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងវេជ្ជ. **អ៊ឹង ប៊ុនសាង** អនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកែប ដែលបានផ្តល់មតិសំណេះសំណាល និងប្រកាសបើកអង្គសិក្ខាសាលា។

សិក្ខាសាលានេះមានការចូលរួមពីផ្នែកជំនាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដូចជាៈ ផ្នែក AIDS Care ផ្នែក BCC ផ្នែក STI និងផ្នែក VCCT គ្លីនិក NCHADS និងមានការចូលរួមពី ប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុម ART មកពីតាមបណ្តាខេត្តជាជា និងអង្គការដៃគូ ដូចជា PC AHF សរុបចំនួន ៤៤ នាក់។ សិក្ខាសាលាមានការធ្វើបទបង្ហាញពីលទ្ធផលដែលសម្រេចបានទៅតាមសូចនាករសំខាន់ៗទាក់ទងនឹង៩៥ទី១៖ ចំនួនអ្នកមានតេស្តប្រតិកម្មរកឃើញថ្មី ភាគរយអ្នកបញ្ជាក់ថាវិជ្ជមាន HIV បានចុះឈ្មោះនៅសេវា ART ចំនួន HIVST បានធ្វើតេស្តបញ្ជាក់ មានលទ្ធផលតេស្តបញ្ជាក់វិជ្ជមាន HIV និងលទ្ធផលសម្រេចបាននៃសូចនាករសំខាន់ៗទាក់ទងនឹង ៩៥ទី២ និង៩៥ទី៣៖ ភាគរយអ្នកជំងឺ ART ដែលបានស្លាប់ អ្នកជំងឺខកណាត់ និងបាត់មុខដែលបានដាក់អោយទទួលសេវាវិញ ការពិនិត្យតាមការណាត់ មុនថ្ងៃណាត់ យឺតជាងថ្នាំបម្រុង យឺតអស់ថ្នាំបម្រុង និងកំណត់បញ្ហាអាទិភាព មូលហេតុដែលទាក់ទងនឹងលទ្ធផលនៃសូចនាករទាប និងរៀបចំផែនការសកម្មភាពដើម្បីកែលម្អរទៅ។



